ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គម

BSDA

BUDDHISM FOR SOCIAL DEVELOPMENT ACTION ORGANIZATION

# គោលនយោបាយប្រឆាំងអំពើពុករលួយ

# Anti-Fraud Policy

2024 កែប្រែលើកទី៦

# មាតិកា
Content

**ទំព័រ**
Page


អំពីអង្គការ BSDA............................................................................................................៣
ប្រការ១.និយមន័យ.........................................................................................................៥
ប្រការ២.វិសាលភាព........................................................................................................៥
ប្រការ៣.គោលបំណង.......................................................................................................៥
ប្រការ៤.បទបញ្ញាត្តិទូទៅ....................................................................................................៥
ប្រការ៥.ទំនួលខុសត្រូវ.....................................................................................................៦
ប្រការ៦.ដំណើរការរាយការណ៍ពីការសង្ស័យចំពោះការប្រព្រឹត្តអំពើពុករលួយ......................................៦
ប្រការ៧.ដំណើរការឆ្លើយតបទៅការរាយការណ៍ពីអំពើពុករលួយ........................................................៧
ប្រការ៨.សកម្មភាពផ្នែកវិន័យ...............................................................................................៧

# សេចក្តីផ្តើម

## សាវតារបស់ BSDA

អង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីការអភិវឌ្ឍសង្គម(BSDA) គឺជាអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកមួយដែលត្រូវបានបង្កើតឡើងនៅថ្ងៃទី៥ ខែមករា ឆ្នាំ២០០៥ ដោយព្រះសង្ឃ ៧អង្គ នៅវត្តនគរបាជ័យ។ក្រសួងមហាផ្ទៃបានទទួលស្គាល់BSDAតាមរយៈលេខ១៦២ចុះថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០០៥ ។ BSDAមិនធ្វើការបម្រើឱ្យគណបក្សនយោបាយណាឬក៏ផ្សព្វផ្សាយពីសាសនារបស់សមាជិកខ្លួនឡើយ។

អង្គការ BSDA គឺផ្តោតតែលើការអភិវឌ្ឍសង្គម និងជួយប្រជាជនក្រីក្របំផុតដែលកំពុងរស់ក្នុងសហគមន៍ក្រីក្រ។

## អត្តសញ្ញាណ

ស.ព.អ.ស ជាអង្គការសហគមន៍បានបង្កើតឡើងនៅលើ គោលការណ៍ព្រះពុទ្ធសាសនានៃធម៌មេត្តា ដើម្បីផ្តល់អំណាចដល់ប្រជាជនដែលងាយរងគ្រោះ និងដើម្បីលើកកម្ពស់ការចូលរួមទំនាក់ទំនងល្អក្នុងការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គម ដើម្បីរួមចំណែកលុបបំបាត់នៃភាពរងគ្រោះឬក្រីក្រ។

## គុណតម្លៃ

ជាឫសគល់ក្នុងការបង្រៀនរបស់ព្រះពុទ្ធដោយអនុវត្តធម៌មេត្តាBSDA បានប្រកាន់ខ្ជាប់និងលើក កម្ពស់គុណតម្លៃរបស់ខ្លួនដូចខាងក្រោម:

- បម្រើអ្នកក្រីក្រៈកែលម្អជី វភាពរស់នៅរបស់គ្រួសារអ្នកក្រីក្រ។
- សាមគ្គីភាពៈកសាង ជំនឿជាក់ ភាពស្មោះត្រង់ និងការគោរពគ្នាដូចជាគ្រួសារ។
- លទ្ធិប្រជាធិបតេយ្យៈលើកកំពស់សំលេងរួមពីសហគមន៍ អ្នកពាក់ព័ន្ធ និងបុគ្គលិក គ្រប់លំដាប់ថ្នាក់នៅក្នុងដំណើរការធ្វើការសេចក្តីសម្រេចអ្វីមួយ។
- នវានុវត្តន៍: ការផ្តល់នូវឱកាសតែមួយគត់សម្រាប់ប្រជាពលរដ្ឋ ក្នុងការដោះស្រាយបញ្ហារបស់ពួកគេ តាមរយៈព័ត៌មានបច្ចេកវិទ្យាគមនាគមន៍ (ICT) និងការគិតត្រិះរិះពិចារណា។
- សុចរិតភាព និងគណនេយ្យភាពៈនៅក្នុងការគ្រប់គ្រងនិងការប្រើប្រាស់ជំនួយ! ត្រូវបានទទួលខុសត្រូវខ្ពស់ និងមានតម្លាភាពដល់សហគមន៍ ម្ចាស់ជំនួយ និងអ្នកពាក់ព័ន្ធ។

## ទស្សនៈវិស័យ

អង្គការ ស.ព.អ.ស ចង់ឃើញសង្គមដែលប្រជាពលរដ្ឋរស់នៅដោយឯករាជ្យនិងអាចចិញ្ចឹមជីវិតបានដោយខ្លួនឯង។

## បេសកកម្ម

ស.ព.អ.ស គឺដើម្បីជំរុញ និងលើកកម្ពស់ជីវភាពនៃការរស់នៅរបស់ប្រជាពលរដ្ឋ ដែលងាយរងគ្រោះ ជាពិសេសស្ត្រីកុមារ និងយុវជន តាមរយៈវិស័យអប់រំ បណ្តុះបណ្តាលវិជ្ជាជីវៈ សហគ្រាសសង្គម អភិបាលកិច្ចល្អ និងការផ្តួចផ្តើមអភិវឌ្ឍន៍ជីវភាពរស់នៅ និងកម្មវិធីនវានុវត្តន៍ជាដៃគូជាមួយអ្នកផ្សេងៗ។

## ទិសដៅយុទ្ធសាស្ត្រ

- អនុវត្តន៍កម្មវិធីចម្រុះ និងប្រកបដោយភាពច្នៃប្រឌិត
- ការបង្កើតទំនាក់ទំនងរឹងមាំ
- ការប្រកបមុខរបររស់នៅប្រកបដោយនិរន្តរភាព
- ការបង្កើតយុទ្ធសាស្ត្រគៀគរថវិកាប្រកបដោយនិរន្តរភាព
- បន្តការរៀន និងរីកចម្រើន
- ការកសាងសមត្ថភាពបុគ្គលិក

## គោលបំណង

ដើម្បីធានានិរន្តរភាព គណនេយ្យភាពតម្លាភាព សុវត្ថិភាពបុគ្គលិកនិងភាពត្រឹមត្រូវស្របតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។

## វិសាលភាព

គោលនយោបាយនេះអនុវត្តទៅលើថ្នាក់ដឹកនាំនិងបុគ្គលិករបស់អង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍន៍សង្គមទូទាំងប្រទេសកម្ពុជា។

**ប្រការ១.និយមន័យ**

គោលនយោបាយប្រឆាំងអំពើពុករលួយគឺជាការកេងបន្លំ ឬបិទបាំងនៃអំពើទុច្ចរិតដែលធ្វើឲ្យខាតបង់ ឬអាចបាត់បង់ធនធាន របស់អង្គការ ទោះបីផលប្រយោជន៍ផ្ទាល់ខ្លួនឬ អ្នកដទៃក៏ដោយ។

**ប្រការ២.វិសាលភាព៖** គោលនយោបាយនេះត្រូវបានអនុវត្តចំពោះអំពើពុករលួយគ្រប់រូបភាពគ្រប់វិស័យ គ្រប់អ្នកស្ម័គ្រចិត្ត បុគ្គលិក ថ្នាក់ដឹកនាំ សមាជិកក្រុមប្រឹក្សាភិបាល ទូទាំងតំបន់គោលដៅរបស់អង្គការដែលបានប្រព្រឹត្តក្រោយពេលដែលគោលនយោបាយនេះមានអានុភាពអនុវត្ត។

**ប្រការ៣.គោលបំណង**

ដើម្បីធានាស្តង់ដារខ្ពស់ផ្នែកច្បាប់ និងអាកប្បកិរិយាប្រកបដោយសីលធម៌ពាសពេញអង្គការសកម្មភាពព្រះពុទ្ធសាសនាដើម្បីអភិវឌ្ឍសង្គម។

**ប្រការ៤.បទបញ្ញាត្តិទូទៅ**

- អង្គការ សកម្មភាពព្រះពុទ្ធសាសនាដើម្បីការអភិវឌ្ឍសង្គម បានប្តេជ្ញាឆ្ពោះទៅរកស្តង់ដារសីលធម៌និងច្បាប់ខ្ពស់។ សមាជិកបុគ្គលិកទាំងអស់ ក៏ដូចជាអ្នកស្ម័គ្រចិត្ត ទីប្រឹក្សា អ្នកទទួល ការងារ អង្គការដៃគូ និងក្រុមផ្សេងៗទៀតដែលមានទំនាក់ទំនងផ្នែកហិរញ្ញវត្ថុ ឬការទុកចិត្តជា មួយ BSDA ត្រូវបានរំពឹងថាចែករំលែកការប្តេជ្ញាចិត្តនេះ។ គោលបំណាងនៃសេចក្តីថ្លែងការណ៍ នេះគឺដើម្បីកំណត់គោលនយោបាយរបស់BSDAចំពោះការការពារ និងការលុបបំបាត់អំពីពុក រលួយ និងដំណើរការដែលត្រូវតាមដានប្រសិនបើមានការសង្ស័យឬស៊ើបរកឃើញអំពើពុក រលួយ។
- មិនមាននិយមន័យផ្នែកច្បាប់ជាក់លាក់ណាមួយទេអំពីអំពើពុករលួយ។ នៅក្នុងផ្នែកសប្បុរ និង ទីសាធារណៈ ពាក្យនេះត្រូវបានគេប្រើដើម្បីពណ៌នាសកម្មភាពដូចជា ការកេងប្រវ័ញ្ច ការសូក ប៉ាន់ ការជំរិតយកប្រាក់ ការពុករលួយ ការលួច អំពើក្បត់ ការកេងបន្លំ និងការលាក់បាំងភាពពិតប្រាកដនៃសម្ភារៈ។ សម្រាប់គោលបំណងអនុវត្តជាក់ស្តែង អំពើពុករលួយអាចត្រូវបាន កំណត់ថាជាការប្រើប្រាស់ការបំភាន់ ក្នុងបំណងទទួលបានផលប្រយោជន៍ហិរញ្ញវត្ថុដោយ អយុត្តិធម៌ ឬខុសច្បាប់ ឬផលប្រយោជន៍ដែលមិនស្មើភាព។
- អំពើពុករលួយក្នុងករណីណាក៏ដោយ តំណាងឱ្យការគំរាមកំហែង ចំពោះកិត្តិស័ព្ទល្អរបស់ BSDA និងថវិកាជំនួយដែលទទួលខុសត្រូវ។ដូច្នេះ BSDA បានតាំងចិត្តដើម្បីលុបបំបាត់អំពើពុករលួយនៅក្នុងអង្គការនិងដៃគូរបស់ខ្លួននិងធ្វើការសង្កេតយ៉ាងហ្មត់ចត់អំពីករណីបែបនោះ
- គោលនយោបាយរបស់ BSDA គឺដើម្បីបង្កើនការយល់ដឹងរបស់បុគ្គលិក ចំពោះការប្រឈមនឹងអំពើពុករលួយ ដើម្បីបង្កើត និងរក្សាការគ្រប់គ្រងក្នុងបំណងការពារ និងលុបបំបាត់អំពើពុក រលួយ និងធ្វើសកម្មភាពយ៉ាងមានប្រសិទ្ធិភាពនៅពេលណាដែលមានការសង្ស័យ ឬរកឃើញ អំពើពុករលួយ។
- BSDA ចាត់ទុកវាជាភារកិច្ចរបស់និយោជិតទាំងអស់គ្នាដែលត្រូវធ្វើសកម្មភាពយ៉ាងស្មោះត្រង់ និងមានសេចក្តីថ្លៃថ្នូរគ្រប់ពេលវេលា និងត្រូវរាយការណ៍ពីការសង្ស័យ ចំពោះភាពមិនប្រក្រតីដោយមិនត្រូវពន្យារពេលឡើយ។
- វាក៏ជាគោលនយោបាយរបស់ BSDA ផងដែរដែលមិនមាននិយោជិតណា នឹងទទួលរងការឈឺ

ចាប់តាមគ្រប់រូបភាពដែលជាលទ្ធផល នៃការរាយការណ៍ពីការសង្ស័យ ក្នុងការប្រព្រឹត្តដោយសមហេតុផល។

**ប្រការ៥.ទំនួលខុសត្រូវ**

- គណៈកម្មាធិការដឹកនាំ និងនាយកប្រតិបត្តិរបស់ BSDA ទទួលខុសត្រូវក្នុងការកំណត់បញ្ហាប្រឈមចំបងៗដែល BSDA បានជួបប្រទះ និងក្នុងការធានាថា ប្រព័ន្ធដំណើរការ និងការគ្រប់គ្រងសមរម្យស្ថិតនៅទីកន្លែងត្រឹមត្រូវ ដើម្បីកាត់បន្ថយភាពដែលអាចមានអំពើពុករលួយកើតឡើង។ ពួកគេក៏ទទួលខុសត្រូវផងដែរសម្រាប់ផ្តល់នូវការឆ្លើយតបរបស់ BSDA ចំពោះការសង្ស័យ ឬការពិតអំពីអំពើពុករលួយ។
- ដោយមានជំនួយពីអ្នកគ្រប់គ្រងកម្មវិធី អ្នកសម្របសម្រួលកម្មវិធី និងមន្រ្តីគម្រោង នាយកប្រតិបត្តិទទួលខុសត្រូវលើការគ្រប់គ្រងប្រចាំថ្ងៃរបស់ BSDA ដូច្នេះហើយ ត្រូវទទួលខុសត្រូវថែរក្សាប្រព័ន្ធ និងការគ្រប់គ្រងដែលរចនាឡើងដោយធ្វើឱ្យកើតឡើងនៃអំពើពុករលួយនៅក្នុងអង្គការមានកម្រិតទាបបំផុត។
- អ្នកគ្រប់គ្រងទាំងអស់ទទួលខុសត្រូវសម្រាប់ការធានាថា និយោជិតបានដឹងពីការប្រឈមនឹងការប្រព្រឹត្តអំពើពុករលួយ ស៊ាំជាមួយនឹងសកម្មភាពមិនសមរម្យ ដែលអាចរំពឹងថានឹងកើតឡើងនៅក្នុងដែននៃទំនួលខុសត្រូវរបស់ពួកគេនិងក្រើនរំលឹកសម្រាប់សញ្ញាមិនប្រក្រតីនានា។ អ្នកគ្រប់គ្រងក៏ទទួលខុសត្រូវផងដែរ ក្នុងការធ្វើឱ្យប្រាកដថានិយោជិតពេញចិត្តចំពោះប្រព័ន្ធដែលបានបង្កើតឡើងដើម្បីការពារ និងលុបបំបាត់សកម្មភាពពុករលួយ។
- អ្នកគ្រប់គ្រងហិរញ្ញវត្ថុរបស់ BSDA គឺមានទំនួលខុសត្រូវពិសេសសម្រាប់ការរៀបចំ ការអនុវត្តការកែលម្អ និងរក្សាប្រព័ន្ធដើម្បីការពារ និងលុបបំបាត់សកម្មភាពពុករលួយ។ ការយល់ព្រមជាមួយនឹងប្រព័ន្ធត្រូវតែទទួលបានការបញ្ជាក់ពីសវនករទាំងក្នុងនិងក្រៅអង្គការ។ វាក៏ជាទំនួលខុសត្រូវរបស់អ្នកគ្រប់គ្រងហិរញ្ញវត្ថុរបស់ BSDA ផងដែរដើម្បីរក្សាបញ្ជីដែលរាយការណ៍ ពីករណីសង្ស័យទាក់ទងនឹងអពើពុករលួយ។
- និយោជិតទាំងអស់មានភារកិច្ចត្រូវធ្វើសកម្មភាពយ៉ាងស្មោះត្រង់និងប្រកបដោយសេចក្តីថ្លៃថ្នូរគ្រប់ពេលវេលានិងត្រូវរាយការណ៍ពីការសង្ស័យចំពោះភាពមិនប្រក្រតីដោយមិនពន្យាពេល។

**ប្រការ៦.ដំណើរការរាយការណ៍ពីការសង្ស័យចំពោះការប្រព្រឹត្តអំពើពុករលួយ**

- និយោជិតដែលមានកង្វល់ពីសកម្មភាពរបស់មិត្តរួមការងារ ហើយសង្ស័យថាបានប្រព្រឹត្តអំពើពុករលួយ ឬមានគម្រោងប្រព្រឹត្ត មិនគួរផ្តល់គំនិតដល់ជនសង្ស័យទាក់ទងនឹងការសង្ស័យរបស់ពួកគេ ដោយការធ្វើបែបនេះនឹងធ្វើឱ្យមានអន្តរាយដល់ការស៊ើបអង្កេត។ ព័ត៌មានលម្អិតគួរត្រូវបានរាយការណ៍ភ្លាមៗដោយនយោជិតទៅកាន់អ្នកគ្រប់គ្រងរបស់គាត់/នាង ឬទៅកាន់អ្នកគ្រប់គ្រងផ្នែកធនធានមនុស្សនិងរដ្ឋបាលឬនាយកប្រតិបត្តិ ឬដាក់ក្នុងប្រអប់មតិយោបល់។ ប្រសិនបើក្នុងមូលហេតុណាក៏ដោយដែលនយោជិតមានអារម្មណ៍ថាមិនអាចពិភាក្សាបញ្ហាជាមួយអ្នកគ្រប់គ្រង ឬប្រើប្រអប់មតិយោបល់ ពួកគេគួរទាក់ទងជាមួយគណៈកម្មាការដឹកនាំ។

- អ្នកគ្រប់គ្រងដែលទទួលបានការរាយការណ៍ពីករណីសង្ស័យ មិនគួរធ្វើការស៊ើបអង្កេតទៅជាការចោទប្រកាន់ទេ ប៉ុន្តែគួររាយការណ៍បញ្ហានេះជាបន្ទាប់ទៅកាន់នាយកប្រតិបត្តិ។ ប្រសិនបើក្នុងមូលហេតុណាក៏ដោយដែលអ្នកគ្រប់គ្រងមានអារម្មណ៍ថាមិនអាចពិភាក្សាបញ្ហា ជាមួយនាយកប្រតិបត្តិ ឬប្រើប្រអប់មតិយោបល់ ពួកគេគួរទាក់ទងជាមួយគណៈកម្មាការដឹកនាំ។

**ប្រការ៧.ដំណើរការឆ្លើយតបទៅការរាយការណ៍ពីអំពើពុករលួយ**

- ប្រសិនបើអ្នកគ្រប់គ្រងហិរញ្ញវត្ថុសន្និដ្ឋានថា ការចោទប្រកាន់មានភស្តុតាង ការស៊ើបអង្កេតមួយគួរត្រូវបានបង្កើតឡើង។ អ្នកគ្រប់គ្រងហិរញ្ញវត្ថុ និងនាយកប្រតិបត្តិជាអ្នកទទួលខុសត្រូវសម្រាប់ការកំណត់ពីចរិតលក្ខណៈនៃការស៊ើបអង្កេតនោះ។
- ការស៊ើបអង្កេបនោះមានបំណង បង្កើតវិសាលភាពនៃអំពើពុករលួយ កំណត់អ្នកប្រព្រឹត្តបទល្មើស និងកំណត់ថាតើអ្នកដទៃពាក់ព័ន្ធ ឬអត់។ វាក៏នឹងពិចារណាផងដែរថាតើការខ្វះចន្លោះនៃប្រព័ន្ធ និងការគ្រប់គ្រងផ្ទៃក្នុងនាំឱ្យមានការប្រព្រឹត្តពុករលួយ ឬក៏បញ្ហាកើតឡើងដោយសារការខកខានមិនបានធានាការយល់ព្រមជាមួយប្រព័ន្ធដែលមាន។
- ការមិនយល់ព្រមជាមួយប្រព័ន្ធដែលមាន អាចជាភស្តុតាងនៃការធ្វើប្រហែសចំពោះផ្នែកគ្រប់គ្រង និងអ្នកទទួលខុសត្រូវនឹងត្រូវប្រឈមនឹងការដំណើរការដាក់ពិន័យ។ ការធ្វេសប្រហែសធ្ងន់ធ្ងរចំពោះផ្នែកគ្រប់គ្រង ឬនយោជិតនឹងត្រូវចាត់ទុកជាមូលដ្ឋានសម្រាប់ការបញ្ឈប់។

**ប្រការ៨.សកម្មភាពផ្នែកវិន័យ**

- វាជាគោលនយោបាយរបស់ BSDAដែលត្រូវរាយការណ៍ពីការសង្ស័យចំពោះការប្រព្រឹត្តអំពើពុករលួយដើម្បីកាន់ប៉ូលីស ដែលអាចធ្វើបណ្ដឹងបទល្មើស។ ទោះជាបញ្ហាត្រូវបានបញ្ជូនទៅកាន់ប៉ូលីស ឬអត់ សកម្មភាពផ្នែកវិន័យនឹងត្រូវដាក់ចំពោះនិយោជិតដែលពាក់ព័ន្ធ ហើយអាចឱ្យផលជាការបញ្ឈប់។
- ការចោទប្រកាន់ដែលបង្ហាញថាមិនសមហេតុសមផល និងធ្វើឡើងក្នុងបំណងព្យាបាទ អាចត្រូវបានចាត់ទុកជាសកម្មភាព នៃការប្រព្រឹត្តដោយគំរោល ចំពោះនិយោជិតដែលពាក់ព័ន្ធ។ សកម្មភាពផ្នែកវិន័យនឹងត្រូវដាក់ចំពោះនិយោជិតដែលធ្វើការចោទប្រកាន់បែបនេះហើយអាចឱ្យផលជាការបញ្ឈប់ពីការងារ។(មើលឧបសម្ព័ន្ធ-03)

ខ្លឹមសារ ឬបទប្បញ្ញត្តិទាំងឡាយ ដែលផ្ទុយនឹងគោលនយោបាយខាងលើត្រូវទុកជានិរាករណ៍។

ថ្ងៃពុធ ៨រោច ខែចេត្រ ឆ្នាំរោង ឆស័ក ព.ស.២៥៦៧

កំពង់ចាម ថ្ងៃទី ០១ ខែឧសភា ឆ្នាំ២០២៤

**ហត្ថលេខា**

**ឃឺត ព្រីដេនប៊ឺក**

Kurt Bredenberg

**ប្រធានក្រុមប្រឹក្សាភិបាល**

Chairman of Board of Director

**ហត្ថលេខា**

**ឈុន ស្រស់**

Chhon Srors

**នាយិកាប្រតិបត្តិ**

Executive Director